## ការបិតប៉ះធ្មេញ

ការបិតប៉ះ គឺជាការបិតបំពេញ រឺជួសជុលធ្មេញ ។

វាតំរូវអោយធ្វើ ប្រសិនបើធ្មេញ:

- ត្រូវបានបំផ្លាញដោយសារការពុកធ្មេញ
- មានការខូចខាតរូបរាងធ្មេញ
- មានការបាត់បង់ផ្ទៃធ្មេញដោយសារ abrasion, attrition, erosion
- មានពណ៌មិនល្អ រឺ រូបរាងមិនល្អ

**Abrasion:** បាត់បង់ធ្មេញដោយសារការសឹកពីសមាសភាគបន្ថែម--ការដុសធ្មេញ

**Attrition:** បាត់បង់ធ្មេញដោយសារការសង្កៀតនៃធ្មេញ ។

**Erosion**: បាត់បង់ធ្មេញដោយសារអាហារជាតិ អាស៊ីត ។

យើងជួសជុល ឬ បិតប៉ះធ្មេញ:

- ដើម្បីឱ្យអាចញ៉ាំ និង ទំពារ
- ដើម្បីសាងសង់ ឬ ធ្វើអោយប្រសើរនូវរូបរាងឡើងវិញ
- ដើម្បីការពារ ការពុកធ្មេញថែមទៀតនៅលើធ្មេញ
- ដើម្បីជួយរក្សាធ្មេញដទៃទៀត និង អញ្ចាញអោយមានសុខភាពល្អ –
  - ធ្មេញដែលមានរូបរាងត្រឹមត្រូវល្អ ជួយកុំឱ្យអាហារចូល និង ការពារមិនអោយមាន stagnation areas ។

**Stagnation area:** ជាចន្លោះដែលសំអែកធ្មេញ និង អាហារអាចប្រមូលផ្តុំ ហើយវាពិបាកក្នុងការសំអាត ។

យើងអាចធ្វើការបិតប៉ះ ជួសជុលធ្មេញដោយប្រើ:

- សំភារៈ បិតបំពេញធ្មេញ
- Inlay / Onlay
- Crown / Veneer

## សំភារៈបិតប៉ះធ្មេញ

សំភារៈបិតប៉ះបណ្តោះអាសន្នត្រូវបានគេប្រើរហូតដល់ ការបិតប៉ះសំរេចនោះ ត្រូវបានគេធ្វើរួច ។

ពួកវាជាសំភារៈទន់ ដែលមិនអាចប្រើបានរយៈពេលយូរទេ ។

ម្សៅ Zinc Oxide និង Eugenol (ជួនកាល ត្រូវបានគេហៅថា oil of cloves) ត្រូវបានលាយជាមួយគ្នាអោយក្លាយជាម្សៅខាប់ ។

វារឹងនៅរយៈពេល ៤ ទៅ ៥ នាទី ។ វាមិនស្អិតជាប់នឹងធ្មេញទេ ដូច្នេះត្រូវមានប្រហោងដើម្បីដាក់ការបិតប៉ះបណ្តោះអាសន្ននោះចូល ។

### AMALGAM:

Amalgam ជាសំភារៈបិតប៉ះដែលគេនិយមប្រើបំផុត ជាពិសេស សំរាប់ធ្មេញក្រោយ ។ វាអាចប្រើបានរយៈពេលមួយជីវិត ប្រសិនបើ ប្រើត្រឹមត្រូវ ។ Amalgam ជាល្បាយរវាង បារត និង សមាសភាគលោហៈ ។ សមាសភាគលោហៈនោះ មាន ប្រាក់ ទង់ដែង សំណប៉ាហាំង និង សង្កសី ។

ជាធម្មតា amalgam ប្រភេទគ្រាប់ត្រូវបានគេប្រើប្រាស់ ហើយប្រភេទជាគ្រាប់នោះអាចមានរង្វាស់ ១, ២, ៣, រឺ ៥ ។

បារតដែលជាសារធាតុសំខាន់នៃ amalgam គឺជាជាតិពុល ហើយវាត្រូវតែប្រើប្រាស់ដោយយកចិត្តទុកដាក់ខ្ពស់បំផុត។ បារតស្ថិតនៅក្នុងសីតុណ្ហភាពនៃបន្ទប់ នឹងហួត ហើយបារតនោះស្ថិតនៅក្នុងអាកាស អាចត្រូវបានស្រូបចូលក្នុងខ្លួន។ បារតក៏នឹងអាចជ្រាបចូលតាមស្បែកផងដែរ។ បារតដែលខ្លួនប្រាណយើងបានស្រូបចូល មិនងាយនឹងបញ្ចេញចោលវិញទេ ហើយរយៈពេលដែលខ្លួនប្រាណយើង ប៉ះបារតនោះកាន់តែយូរ នោះគ្រោះថ្នាក់កាន់តែខ្ពស់។ ស្រោមដៃគួរតែត្រូវបានពាក់គ្រប់ពេល នៅពេលធ្វើការជាមួយ amalgam។

ជាធម្មតាជំនួយការទន្តពេទ្យ នឹងដាក់បញ្ចូល amalgam ដែលទើបនឹងលាយរួច ចូលក្នុងប្រហោងធ្មេញដែលរៀបចំរួចដោយប្រើ amalgam carrier (ប្រដាប់ចាប់យក amalgam) ចូរចងចាំថា ត្រូវប្រើ amalgam carrier ណាដែលសក្តិសមបំផុត (ត្រង់ ឬ កោង) មកប្រើ។ ដំបូង amalgam ត្រូវបានដាក់ចូលទៅចំណុចដែលជ្រៅបំផុតនៃប្រហោងធ្មេញ ហើយសង្កត់វាអោយចូលក្នុងទីតាំងនោះ ដូចនេះចំពោះធ្មេញលើ វាមិនរបូតចេញទេ មុនពេលដែលទន្តពេទ្យធ្វើការសង្កត់ចូលក្នុងទីតាំងនេះ។ ប្រសិនបើទន្តពេទ្យសង្កត់ amalgam កាន់តែខ្លាំងចូលទៅក្នុងប្រហោងធ្មេញ នោះការប៉ះនោះនឹងកាន់តែល្អ។

ដំបូងទន្តពេទ្យ នឹងប្រាប់អ្នកថា បរិមាណ amalgam ប៉ុណ្ណាដែលត្រូវការ ហើយពេលណាត្រូវចាប់ផ្តើមលាយវា។ ប្រហោងធ្មេញនោះ ជានិច្ចកាល ត្រូវបំពេញដោយ amalgam ឱ្យច្រើនលើសបន្តិច ហើយរួចមក ត្រូវឆាបយកវាចេញដោយទន្តពេទ្យ រហូតដល់រូបរាងដែលត្រូវការ។ ជានិច្ចកាល ត្រូវនិយាយថា "នេះជា amalgam ទីពីរចុងក្រោយ" ប្រសិនបើ ទន្តពេទ្យត្រូវការបន្ថែមទៀត អ្នកនឹងត្រូវបានគេប្រាប់ថា amalgam ប៉ុណ្ណា នឹងត្រូវលាយបន្ថែម។

រាល់ amalgam ដែលនៅសល់ រឺ amalgam ពីបំណះធ្មេញចាស់ ត្រូវរក្សាទុកក្នុងដបដាក់កាកសំណល់ amalgam ជាពិសេស--អាចជាដបដែលមាន ដែលសំរាប់ស្រូបយកជាតិបារត រឺ ដាក់នៅក្រោមទឹក រឺ សូលុយស្យុងរក្សារូបភាពសំរាប់លាងហ្វីលថតដែលប្រើរួច។ គ្រាប់ capsules របស់ amalgam ត្រូវបិតអោយជិត ហើយ ដាក់ចូលក្នុងប្រអប់ជាពិសេស ដែលមានដែលសំរាប់ស្រូបយកជាតិបារត។